# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការតំលើងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា ទៅជាមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១/អនក្រ/បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងអប់រំ យុវជន និង កីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :**

ត្រូវបានតំលើងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា អោយទៅជា មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ចំណុះអគ្គនាយកដ្ឋាន យុវជន និង កីឡា នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២ :**

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មានមុខងារ និង ភារកិច្ចដូចខាងក្រោម ÷

- ប្រមូលផ្តុំគ្រូបង្វឹក អនុរក្ស កីឡាករ កីឡាការិនី ជំរើសជាតិ គ្រប់វិញ្ញាសាមកធ្វើការ បំប៉ន ហាត់ហ្វឹកហ្វឺន ដើម្បីត្រៀមលក្ខណៈចូលរួមប្រកួតលក្ខណៈអន្តរជាតិ
- សហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និង គ្រប់សហព័ន្ធកីឡាជាតិ ក្នុងការជ្រើសរើសកីឡាករ កីឡាការិនី ជំរើសជាតិ
- រៀបចំបង្កើត និង គ្រប់គ្រងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡាតាមភូមិភាគ
- រៀបចំផែនការហាត់ហ្វឹកហ្វឺន និង ធ្វើការត្រួតពិនិត្យ តាមដានលទ្ធផលបច្ចេកទេស លើគ្រប់វិញ្ញាសា ។

**មាត្រា ៣ :**

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មានឋានៈ និង បុព្វសិទ្ធ ស្មើនាយកដ្ឋាន ដែល ប្រធាន មួយរូប និ[illegible]ន មួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤ :**

ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់ មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៥ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ.